# នីតិអន្តរជាតិសាធារណៈ
# PUBLIC INTERNATIONAL LAW

## មេរៀនទី ១៤

LECTURE 14

## ទំនាក់ទំនងការទូត

DIPLOMATIC RELATIONS

# មាតិកា

- កម្មវត្ថុនៃមេរៀន
- ផ្នែកទី១ សេចក្ដីផ្ដើម
- ផ្នែកទី២ ការភ្ជាប់ និងផ្ដាច់ទំនាក់ទំនងការទូត
  - សញ្ញាណទូទៅ
  - បេសកកម្មការទូត
  - តួនាទីនៃបេសកកម្មការទូត
- ផ្នែកទី៣ អភ័យឯកសិទ្ធិការទូត
  - សញ្ញាណទូទៅ
  - ខ្លឹមសារអភ័យឯកសិទ្ធីការទូត
  - កាតព្វកិច្ចភ្នាក់ងារការទូត

# កម្មវត្ថុនៃមេរៀន

នៅក្នុងមេរៀនស្តីពីទំនាក់ទំនងការទូត មានគោលបំណងឲ្យអ្នកសិក្សាបានស្វែងយល់ពី៖

- សារៈសំខាន់នៃទំនាក់ទំនងការទូត
- សមត្ថកិច្ចរបស់រដ្ឋចំពោះភ្នាក់ងារការទូត
- កាតព្វកិច្ចរបស់ភ្នាក់ការទូតចំពោះរដ្ឋម្ចាស់ផ្ទះ
- មូលហេតុមួយចំនួនដែលនាំឲ្យមានការផ្តាច់ទំនាក់ទំនងការទូត

# ផ្នែកទី១ សេចក្ដីផ្ដើម

ក្នុងលក្ខខណ្ឌនៃការបង្កើតរដ្ឋ គឺត្រូវតែមានធាតុផ្សំចំនួនបីជាដាច់ខាត ដែលធាតុផ្សំទាំងនោះរួមមានដូចជា ទឹកដី ប្រជាជន (ប្រជាពលរដ្ឋ) និងអំណាចគ្រប់គ្រង (រដ្ឋាភិបាល)។ ទោះមានធាតុផ្សំទាំងបីនេះដើម្បីបង្កើតរដ្ឋក៏ដោយ ក៏រដ្ឋជាទូទៅត្រូវមានការទទួលស្គាល់ពីសំណាក់រដ្ឋដ៏ទៃ។

# ផ្នែកទី១ សេចក្ដីផ្ដើម

ការទទួលបាននូវការទទួលស្គាល់ពីរដ្ឋដ៏ទៃ មិនមែនជារឿងងាយស្រួលនោះឡើយ ដូច្នេះហើយ ទើបរដ្ឋត្រូវបង្កើតឲ្យមានទំនាក់ទំនងរវាងគ្នាទៅវិញទៅមក។ ការបង្កើតទំនាក់ទំនងរវាងគ្នានេះ អាចត្រូវបានធ្វើឡើងក្នុងឋានៈជាការភ្ជាប់ទំនាក់ទំនងការទូត ឬ ក្នុងឋានៈជាទំនាក់ទំនងកុងស៊ុល។

# ផ្នែកទី១ សេចក្តីផ្តើម

នៅក្នុងមេរៀនេះ យើងនឹសិក្សាតែពីទំនាក់ទំនងការទូត ហើយទំនាក់ទំនងកុងស៊ុល យើងនឹងធ្វើការសិក្សានៅក្នុងមេរៀនទី១៥ ស្តីពីទំនាក់ទំនងកុងស៊ុល។ ទំនាក់ទំនងការទូតគឺជាមធ្យោបាយ ឬ ជាកិច្ចទាំងឡាយដែលរដ្ឋបានបង្កើត និងរក្សាទំនាក់ទំនងគ្នាទៅវិញទៅមកក្នុងសង្គមអន្តរជាតិ។

# ផ្នែកទី១ សេចក្ដីផ្ដើម

ជាយូរលង់ណាមកហើយ ដែលរដ្ឋធ្វើការទទួលស្គាល់គ្នាតាមរយៈការបង្កើតនូវទំនាក់ទំនងការទូតរវាងគ្នាទៅវិញទៅមក ហើយរហូតមកដល់បច្ចុប្បន្ន វប្បធម៌នេះនៅតែមានការពេញនិយម និងនៅតែបន្តអនុវត្តជាហូរហែ រហូតបានរួមគ្នាចងក្រងបង្កើតឲ្យមានបទដ្ឋានច្បាស់លាស់។

# ផ្នែកទី១ សេចក្ដីផ្ដើម

បទដ្ឋានដែលត្រូវបានចង់ក្រងបង្កើតឡើង សម្រាប់ថែរក្សាសណ្ដាប់ធ្នាប់នៅក្នុងការធ្វើទំនាក់ទំនងការទូត គឺអនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៦១ ស្ដីពីទំនាក់ទំនងការទូត។ គោលការណ៍ជាច្រើន ដែលបានបញ្ញត្តិនៅក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ក៏ត្រូវបានលើកឡើងក្នុងការអនុវត្តអនុសញ្ញានេះផងដែរ។

# ផ្នែកទី១ សេចក្ដីផ្ដើម

គោលការណ៍ដែលបានលើកឡើងក្នុងការអនុវត្ត អនុសញ្ញាស្ដីពីទំនាក់ទំនងការទូត រួមមានដូចជា គោលការណ៍សមភាពអធិបតេយ្យ គោលការណ៍នៃការថែរក្សាសន្តិភាព គោលការណ៍ស្ដពីសន្តិសុខអន្តរជាតិ និងជាពិសេសគឺគោលការមិត្តភាពក្នុងការធ្វើទំនាក់ទំនង។

# ផ្នែកទី១ សេចក្តីផ្តើម

ការបង្កើតទំនាក់ទំនងការទូត ក៏ត្រូវស្វែងយល់ពីវប្បធម៌គ្នាទៅវិញទៅមក ក៏ដូចជាពង្រឹង និងព័ង្រីកទំនាក់ទំនងទៅលើវិស័យផ្សេងៗជាច្រើនទៀត ដែលក្នុងនោះរួមមានដូចជាផ្នែកនយោបាយ សេដ្ឋកិច្ច វប្បធម៌ ពាណិជ្ជកម្ម សន្តិសុខ និងសុខាភិបាលនៃប្រទេសទាំងសងខាង។

# ផ្នែកទី១ សេចក្តីផ្តើម

ថ្នាក់ដឹកនាំរដ្ឋ រួមមានដូចជាប្រមុខរដ្ឋ (សម្រាប់កម្ពុជាយើងហៅថា ព្រះប្រមុខរដ្ឋ) ឬ ប្រមុខរដ្ឋាភិបាលបានដើរតួនាទីយ៉ាងសំខាន់មុនគេ ក្នុងការបង្កើតឲ្យមានទំនាក់ទំនងការទូតដោយការធ្វើទស្សនកិច្ចផ្លូវរដ្ឋ ឬ អាចធ្វើនូវសន្និសិទធំៗ ឬ តាមរយៈសន្និសិទ្ធអន្តរជាតិ ជាដើម។

# ផ្នែកទី១ សេចក្ដីផ្ដើម

សម្រាប់ប្រទេសកម្ពុជា បានបង្កើតឲ្យមានទំនាក់ទំនងការទូតជាមួយនិងប្រទេសចិនតាំងពីឆ្នាំ២០៣ នៃគ្រឹះសករាជនិង បានបង្កើតទំនាក់ទំនងការទូតជាមួយប្រទេសឥណ្ឌានាពេលបន្ទរមកទៀត ហើយក៏បានចាប់ផ្ដើទំនាក់ទំនងជាមួយអឺរ៉ុបនៅសតវត្សទី១៥។

# ផ្នែកទី១ សេចក្ដីផ្ដើម

នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៦១ អង្គការសហប្រជាជាតិបាន អនុម័តអនុសញ្ញាទីក្រុងវីយែនស្ដីពីទំនាក់ទំនងការទូត ហើយបានចូលជាធរមាននៅថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៦៤ ដែលបច្ចុប្បន្ននេះរដ្ឋស្ទើតែទាំងអស់នៅលើពិភពលោកបានចូលជាសមាជិកនៃអនុសញ្ញនេះ។

# ផ្នែកទី២ ការភ្ជាប់ និងផ្ដាច់ទំនាក់ទំនងការទូត

- សញ្ញាណទូទៅ

ដូចដែលបានលើកឡើងនៅក្នុងសេចក្ដីផ្ដើម នៃមេរៀននេះ ការបង្កើត (ភ្ជាប់) ទំនាក់ទំនងការទូត គឺជារឿងដ៏សំខាន់សម្រាប់ការបញ្ជាក់ពីការទទួលគ្នាទៅវិញទៅមក (ការទទួលស្គាល់រដ្ឋ)។

# ផ្នែកទី២ ការភ្ជាប់ និងផ្ដាច់ទំនាក់ទំនងការទូត

- សញ្ញាណទូទៅ

នីតិអន្តរជាតិ បានទទួលស្គាល់ចំពោះរដ្ឋនូវសិទ្ធិប្រតិភូ ហើយដែលសិទ្ធិនេះអាចមានលក្ខណៈសកម្ម និងអកម្ម។ សិទ្ធិសកម្ម មានន័យថារដ្ឋដាក់ទូត បញ្ជូនភ្នាក់ងារការទូតរបស់ខ្លួនទៅប្រទេសបដិសណ្ឋារកិច្ច (រដ្ឋម្ចាស់ផ្ទះ) និងសិទ្ធិអកម្ម គឺមានន័យបញ្ច្រាស់មកវិញ។

# ផ្នែកទី២ ការភ្ជាប់ និងផ្ដាច់ទំនាក់ទំនងការទូត

- សញ្ញាណទូទៅ

ទំនាក់ទំនងការទូត ត្រូវបង្កើតឡើងដោយមានការព្រមព្រៀង (កិច្ចព្រមព្រៀង) រវាងរដ្ឋទាំសងខាង។ ការសម្រេចភ្ជាប់ទំនាក់ទំនងការទូត និងការថែរក្សានូវទំនាក់ទំនងការទូត គឺជាឆន្ទានុសិទ្ធិរបស់រដ្ឋនៃរដ្ឋដាក់ទូត និងរដ្ឋម្ចាស់ផ្ទះ។

# ផ្នែកទី២ ការភ្ជាប់ និងផ្តាច់ទំនាក់ទំនងការទូត

- សញ្ញាណទូទៅ

សូមចង់ចាំផងដែរថា ការសម្រេចភ្ជាប់ និងរក្សានូវទំនាក់ទំនងការទូត មានទំនាក់ទំនងគ្នាទាំងស្រុងទៅនឹងការទទួលស្គាល់រដ្ឋ។ ប្រសិនបើមានការប្រកាសផ្តាច់ទំនាក់ទំនងការទូត គឺមានន័យមានផលប៉ះពាល់ដល់ការទទួលស្គាល់រដ្ឋ។

# ផ្នែកទី២ ការភ្ជាប់ និងផ្តាច់ទំនាក់ទំនងការទូត

- សញ្ញាណទូទៅ

ដូចគ្នាផងដែរ ការផ្តាច់នូវទំនាក់ទំនងការទូត វាគឺជាឆន្ទានុសិទ្ធិរបស់រដ្ឋឯករាជ្យ ហើយដែលជាទូទៅកិច្ចនេះកើតឡើងក៏ដោយសារ មានការធ្លាក់ចុះនូវខាងទំនាក់ទំនងខាងផ្នែកនយោបាយនៃរដ្ឋទាំងសងខាង ដូចជាពេលមានសង្គ្រាម។

# ផ្នែកទី២ ការភ្ជាប់ និងផ្ដាច់ទំនាក់ទំនងការទូត

- សញ្ញាណទូទៅ

ការផ្ដាច់ទំនាក់ទំនងការទូត គឺរដ្ឋអាចសម្រេចបិទបេសកកម្មការទូតរបស់ខ្លួនដោយកិច្ចឯកតោភាគី ហើយដែលជាហេតុធ្វើឲ្យរដ្ឋម្ខាងទៀតអនុវត្តនូវគោលការណ៍បដិការ ដោយធ្វើការបិទនូវបេសកកម្មការទូតរបស់ខ្លួនផងដែរ។

# ផ្នែកទី២ ការភ្ជាប់ និងផ្តាច់ទំនាក់ទំនងការទូត

- សញ្ញាណទូទៅ

តាមធម្មតា ក្នុងករណីមានសង្គ្រាមរវាងភាគីទាំងសងខាង ធ្វើឲ្យទំនាក់ទំនងការទូត នឹងត្រូវកាត់ផ្តាច់ដោយស្វ័យប្រវត្ត ឧទាហរណ៍ ការផ្តាច់ទំនាក់ទំនងការទូតរវាងប្រទេសឥណ្ឌា និងប្រទេសប៉ាគីស្ថាន នៅក្នុងឆ្នាំ២០០២។

# ផ្នែកទី២ ការភ្ជាប់ និងផ្តាច់ទំនាក់ទំនងការទូត

- សញ្ញាណទូទៅ

ដូចគ្នានេះផងដែរ អង្គការអន្តរជាតិក៏អាចស្នើសុំឲ្យសមាជិករបស់ខ្លួមបញ្ចប់នូវទំនាក់ទំនងការទូត ជាមួយនិងរដ្ឋណាមួយ ប្រសិនបើរកឃើញថាមានការរំលោភបំពានដោយខុសច្បាប់ណាមួយបានកើតឡើង។

# ផ្នែកទី២ ការផ្ដាច់ និងផ្ដាច់ទំនាក់ទំនងការទូត

- សញ្ញាណទូទៅ

សូមបញ្ជាក់ផងដែរថា បើតាមមាត្រា៤១ នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ បានបញ្ញត្តិថា ការផ្ដាច់ទំនាក់ទំនងការទូតគឺជាទណ្ឌកម្ម ដែលអាចត្រូវបានសម្រេចដោយក្រុមប្រឹក្សាសន្តិសុខ ដើម្បីប្រឆាំងទៅនិងរដ្ឋណាមួយ។

# ផ្នែកទី២ ការភ្ជាប់ និងផ្ដាច់ទំនាក់ទំនងការទូត

- បេសកកម្មការទូត

ជាបេសកកម្មរបស់បុគ្គលិកការទូតទាំងមូល ដោយស្ថិតនៅក្រោមការដឹកនាំរបស់ប្រមុខបេសកកម្មការទូតមួយរូប ដែលជាឯកអគ្គរដ្ឋទូត ឬ ឯកអគ្គរាជទូត ហើយត្រូវបានតែងតាំងដោយរដ្ឋដាក់ទូត ដើម្បីបំពេញមុខងារការទូតនៅរដ្ឋដ៍ទៃ។

# ផ្នែកទី២ ការភ្ជាប់ និងផ្តាច់ទំនាក់ទំនងការទូត

- បេសកកម្មការទូត

ឯកអគ្គរដ្ឋទូត ឬ ឯកអគ្គរាជទូតគឺជាប្រមុខបេសកកម្មការទូត និងអមដោយភ្នាក់ងារការទូតទាំងឡាយដែលរួមានដូជាទីប្រឹក្សាការទូត លេខាការទូត និងអនុព័ន្ធយោធា ជាអាទ៍ជាសហាការីដើម្បីបំពេញមុខងារក្នុងអាណត្តិរបស់ខ្លួន។

# ផ្នែកទី២ ការភ្ជាប់ និងផ្ដាច់ទំនាក់ទំនងការទូត

- បេសកកម្មការទូត

សូមគត់សម្គាល់ថា ចំនួនភ្នាក់ងារការទូត ដែលត្រូវទៅបំពេញបេសកកម្ម ត្រូវតែកំណត់ឡើងដោយកិច្ចព្រមព្រៀងរវាងរដ្ឋដាក់ទូត និងរដ្ឋម្ចាស់ផ្ទះ។ ចំណុចនេះត្រូវបានបញ្ញត្តិនៅក្នុងមាត្រា២ នៃអនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៦១។

# ផ្នែកទី២ ការភ្ជាប់ និងផ្ដាច់ទំនាក់ទំនងការទូត

- បេសកកម្មការទូត

ប្រមុខបេសកកម្មការទូត អាចចូលកាន់មុខងារបាន លុះណាមានការប្រគល់នូវសោរតាំង ជូនទៅរដ្ឋម្ចាស់ផ្ទះ តែផ្ទុយទៅវិញសម្រាប់មន្ត្រីភ្នាក់ងារការទូត គ្រាន់តែធ្វើលិខិតជូនដំណឹងជូនទៅរដ្ឋម្ចាស់ផ្ទះ គឺជាការគ្រប់គ្រាន់។

# ផ្នែកទី២ ការភ្ជាប់ និងផ្ដាច់ទំនាក់ទំនងការទូត

- តួនាទីនៃបេសកកម្មការទូត

នៅក្នុងអនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៦១ ស្ដីពីទំនាក់ទំនងការទូត បានបញ្ញត្តិនូវបញ្ជីរាយនាមបេសកកម្មការទូត ដែលអ្នកការទូតត្រូវបំពេញនៅក្នុងទឹដីនៃរដ្ឋម្ចាស់ផ្ទះ ប៉ុន្តែបញ្ជីនេះ គ្មានការកំម្រិតកំណត់ទេ។

# ផ្នែកទី២ ការភ្ជាប់ និងផ្តាច់ទំនាក់ទំនងការទូត

- តួនាទីនៃបេសកកម្មការទូត
    រួមមានដូចជា៖
    ១. ជាតំណាងឲ្យរដ្ឋដាក់ទូត
    ២. ដើម្បីការពារផលប្រយោជន៍របស់រដ្ឋដាក់ទូត
    ៣. ការពារប្រជជនរបស់ខ្លួនដែលរស់នៅក្នុងទឹកដីរដ្ឋម្ចាស់ផ្ទះ

# ផ្នែកទី២ ការភ្ជាប់ និងផ្តាច់ទំនាក់ទំនងការទូត

- តួនាទីនៃបេសកកម្មការទូត
  រួមមានដូចជា៖
  ៤. ធ្វើការចរចារជាមួយនិងរដ្ឋម្ចាស់ផ្ទះ
  ៥. ផ្តល់ព័តមានឲ្យរដ្ឋដាក់ទូត ពីរដ្ឋម្ចាស់ផ្ទះ
  ៦. រក្សា ពង្រឹង និងពង្រីកទំនាក់ទំនងជាមួយរដ្ឋម្ចាំសផ្ទះ

# ផ្នែកទី៣ អភ័យឯកសិទ្ធិការទូត

- សញ្ញាណទូទៅ

ភ្នាក់ងារការទូតរបស់រដ្ឋដាក់ទូត អនុវត្តនូវមុខងារ និងតួនាទីរបស់ខ្លួនដោយឯករាជ្យ បើប្រៀបធៀនទៅនឹងរដ្ឋម្ចាស់ផ្ទះ។ ទំនាក់ទំនងល្អរវាងរដ្ឋដាក់ទូត នឹងរដ្ឋម្ចាស់ផ្ទះ គឺត្រូវមានការធានាថា គ្មានការបំពារបំពាន ទោះជាស្ថានទូតក៏ដោយ។

# ផ្នែកទី៣ អភ័យឯកសិទ្ធិការទូត

- ខ្លឹមសារអភ័យឯកសិទ្ធិការទូត

ខ្លឹមសារនៃអភ័យឯកសិទ្ធិការទូត គឺមានដូចជា៖

១. ធានាសេរីភាពនៃលិខិតឆ្លើយឆ្លង ឬ ហិបទូត

២. មិនរំលោភបំពានលើភ្នាក់ងារទូត និងគ្រួសារ

៣. មិនបំពានលើស្ថានទូត (រដ្ឋម្ចាស់ផ្ទះមិនចូលក្នុងទីតាំងស្ថានទូតដោយពុំមានការអនុញ្ញាត។

# ផ្នែកទី៣ អភ័យឯកសិទ្ធិការទូត

- ខ្លឹមសារអភ័យឯកសិទ្ធិការទូត

ខ្លឹមសារនៃអភ័យឯកសិទ្ធិការទូត គឺមានដូចជា៖

៤. ការពារទ្រព្យសម្បត្តិ បណ្ណាសារ និងឯកសារផ្សេងៗ

៥. ភ្នាក់ងារទូត និងគ្រួសារ រួចផុតពីយុត្តាធិការរដ្ឋម្ចាស់ផ្ទះ

៦. រួចផុតពីការបង់ពន្ធអាករផ្សេងៗ

# ផ្នែកទី៣ អភ័យឯកសិទ្ធិការទូត

- កាតព្វកិច្ចភ្នាក់ងារការទូត

ជាមួយនិងការទទួលបាននូវអភ័យឯកសិទ្ធិ ភ្នាក់ងារការទូត ត្រូវបំពេញនូវកាតព្វកិច្ចមួយចំនួនផងដែរជាមួយនិងរដ្ឋម្ចាស់ផ្ទះ ដើម្បីធានានូវតុល្យភាពនៃការអនុវត្តសិទ្ធិរបស់ខ្លួនរាងៗខ្លួនទៅវិញទៅមកនៃរដ្ឋដាក់ទូត និងរដ្ឋម្ចាស់ផ្ទះ។

# ផ្នែកទី៣ អភ័យឯកសិទ្ធិការទូត

- កាតព្វកិច្ចភ្នាក់ងារការទូត

ភ្នាក់ងារការទូតត្រូវបំពេញនូវកាតព្វកិច្ចមួយចំនួនដូចជា៖

១. គោរពច្បាប់នានារបស់រដ្ឋម្ចាស់ផ្ទះ

២. មិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋម្ចាស់ផ្ទះ

៣. ប្រើប្រាស់ទីតាំងស្ថានទូតឲ្យស្របច្បាប់ (មិនធ្វើពាណិជ្ជកម្ម ឬ លាក់បាំងគ្រឿងញៀន ជាអាទិ៍ )។

# ផ្នែកទី៣ អភ័យឯកសិទ្ធិការទូត

- កាតព្វកិច្ចភ្នាក់ងារការទូត

កត់សម្គាល់:	គោលការណ៍មិនបំពានលើទីតាំងស្ថានទូតបានចោទជាបញ្ហាចំពោះករណីសិទ្ធិជ្រកកោន។ ប្រសិនបើមានអ្នកស្នើសុំសិទ្ធិជ្រកកោន ដែលជាជនទុច្ចរិត ប្រព្រឹត្តបទល្មើសប្រឆាំងច្បាប់រួម នោះស្ថានទូតត្រូវប្រគល់ជននោះទៅឲ្យរដ្ឋម្ចាស់ផ្ទះវិញ។

មេរៀនទី១៤ ស្តីពីទំនាក់ទំនងការទូត ត្រូវបានបញ្ចប់។ សូមអរគុណ សម្រាប់ការតាមដានដោយយកចិត្តទុកដាក់ពីសំណាក់អ្នកសិក្សាទាំងឡាយ។